# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យហែស្លឹកនៅព្រះសហគមន៍សន្តីម៉ារីញញឹមចំការឡៀង
# តាកែវ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០
# ធ្វើជាលោកស៊ីម៉ូនដើម្បីជួយលីឈើឆ្កាងព្រះយេស៊ូ

**អត្ថបទទី១៖ អេសាយ ៥០,៤-៧**

ព្រះជាអម្ចាស់យាងមកជួយខ្ញុំ ហេតុនេះហើយបានជាខ្ញុំមិនបាក់មុខ ខ្ញុំរក្សាទឹកមុខរឹងប៉ឹង ព្រោះខ្ញុំដឹងថា ខ្ញុំមិនត្រូវអាម៉ាស់ឡើយ។ អស ៥០,៧

**អត្ថបទទី២៖ ភីលីព ២,៦-១១**

ព្រះអង្គបានដាក់ខ្លួន ធ្វើតាមព្រះបញ្ជា រហូតដល់សោយទិវង្គត គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង។ ភីល ២,៨

**ដំណឹងល្អ៖ ម៉ាថាយ ២៦,១៤-២៧,៦៦**

ចូរប្រុងស្មារតី ហើយអធិស្ឋាន កុំឲ្យចាញ់ការល្បួងឡើយ។ វិញ្ញាណរបស់មនុស្សប្រុងប្រៀបជាស្រេចមែន តែខ្លួនគេនៅទន់ខ្សោយទេ។ មថ ២៦,៤១

បងប្អូនជាទីស្រឡាញ់!

អត្ថបទដែលស្តីអំពីការរងទុក្ខលំបាករបស់ព្រះយេស៊ូដែលយើងបានស្តាប់ ប្រសិនបើបងប្អូនបានចាប់អារម្មណ៍អំពីសាច់រឿងទាំងអស់ អំពីរបៀបព្រះយេស៊ូមានព្រះបន្ទូល អំពីសកម្មភាពតួអង្គនីមួយៗរហូតដល់ព្រះយេស៊ូសោយទិវង្គត។ ប្រហែលយើងចាប់អារម្មណ៍អំពីអំពើហិង្សាអំពីការស្អប់បំផុត ពេលយើងឃើញរបៀបដែលគេមកចាប់ព្រះយេស៊ូ មិនមែនគេមកម្នាក់ឯងទេគឺមានក្រុមទាហានដែលមក។ នៅពេលគេទៅដល់កន្លែងមហាបូជាចារ្យ គេហែកអាវលោក គេវាយលោក គេធ្វើបាបលោក គេមើលងាយលោក ណែនាំឲ្យព្រះយេស៊ូពិបាកក្នុងរូបកាយព្រះអង្គ។ ពេលយើងឃើញមហាជនដែលមុននេះ បានកោតសរសើរព្រះយេស៊ូជាព្រះមហាក្សត្រក្រោយមកមហាជនដដែលបានស្រែកយ៉ាងខ្លាំងថា "**ឆ្កាងទៅ!**" គេបានបញ្ចេញការស្អប់របស់គេចំពោះព្រះយេស៊ូ។ នៅពេលគេនាំព្រះយេស៊ូទៅលើភ្នំដើម្បីឆ្កាង នៅពេលនោះគេវាយព្រះយេស៊ូគេដាក់ភួងធ្វើដោយបន្លាទៅលើព្រះសិរសាព្រះអង្គ គេមើលងាយព្រះអង្គ។ សូម្បីតែ ចោរព្រៃពីរនាក់ដែលគេឆ្កាងជាមួយព្រះអង្គ ក៏បានមើលងាយព្រះអង្គថែមទៀត ទាហានក៏មើលងាយ មហាជនក៏មើលងាយ។ **មូលហេតុអ្វីបានជាមានការស្អប់យ៉ាងខ្លាំងដូចនេះចំពោះព្រះយេស៊ូ?** ព្រះយេស៊ូដែលបានធ្វើតែអំពើល្អ ព្រះយេស៊ូដែលបានបង្ហាញតែសេចក្តីសុខសាន្តនិងសេចក្តីស្រឡាញ់ព្រះយេស៊ូដែលណែនាំឲ្យមនុស្សលោកជាសះស្បើយពីជំងឺនានា។

សាវ័ករបស់ព្រះយេស៊ូ ជាមិត្តសម្លាញ់របស់ព្រះអង្គយ៉ាងជិតស្និទ្ធបំផុត ប៉ុន្តែនៅពេលព្រះយេស៊ូត្រៀមខ្លួនដើម្បីរងទុក្ខលំបាក ដោយអធិដ្ឋាន ដោយស្ងៀមស្ងាត់ ព្រះអង្គបានសុំឲ្យគេអធិដ្ឋានជាមួយព្រះអង្គ ប៉ុន្តែក្រុមសាវ័កគេបានដេកលក់។ ក្នុងក្រុមសាវ័ករបស់ព្រះយេស៊ូ មានលោកយ៉ូដាស់អ៊ីស្ការីយ៉ុតបាននាំទាហានមកដើម្បីចាប់ព្រះយេស៊ូ ដោយថើបព្រះអង្គធ្វើជាសញ្ញាថានេះជាព្រះយេស៊ូ។ ថើបជាការបង្ហាញសេចក្តីស្រឡាញ់ ប៉ុន្តែនៅពេលនោះបែរជាការក្បត់ទៅវិញ។ ទោះបី លោកសិលាក៏ភ័យខ្លាចមិនហ៊ានទទួលស្គាល់ព្រះយេស៊ូដែរ ដោយគាត់បានបដិសេធថាមិនស្គាល់ព្រះយេស៊ូបីដង។ នៅពេលនោះ នៅសល់តែស្ត្រីមួយចំនួនដែលនៅពីចម្ងាយ មានលោកស៊ីម៉ូននៃទីក្រុងស៊ីរ៉ែនដែលបានជួយលីឈើឆ្កាងរបស់ព្រះយេស៊ូ និងមានលោកយ៉ូសែបពីក្រុងអារីម៉ាស៊ី ដែលបានជួយរៀបចំផ្នូរដើម្បីដាក់ព្រះសពព្រះយេស៊ូនៅក្នុងរបៀបត្រឹមត្រូវ។

ប្រសិនបើ យើងមើលព្រះយេស៊ូផ្ទុយនឹងបរិយាកាសហិង្សា បរិយាកាសស្អប់ បរិយាកាសមើលងាយជេរប្រមាថ។ របៀបព្រះយេស៊ូ គឺអធិដ្ឋាន ស្ងៀមស្ងាត់ ដាក់ខ្លួន ស្រឡាញ់ នៅលើឈើឆ្កាងទោះបីគេមើលងាយព្រះយេស៊ូក៏ព្រះអង្គនៅស្ងៀមស្ងាត់ ដោយមានព្រះបន្ទូលតែមួយម៉ាត់ថា "**អេលី អេលី ឡាម៉ាសាបាច់ថានី**! ដែលមានន័យថា «ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?"។ នៅពេលព្រះយេស៊ូបានសោយទិវង្គតនៅលើឈើឆ្កាង មានព្រឹត្តិការណ៍មួយដែលណែនាំឲ្យទាំងអស់គ្នាភ្ញាក់ស្មារតី គឺមានវាំងនននៅក្នុងព្រះវិហាររហែកជាពីរ ផែនដីរញ្ជួយ ផ្ទាំងថ្មក៏ប្រេះចេញពីគ្នា ផ្នូរក៏របើកចំហឡើង ហើយសាកសពប្រជាជនដ៏វិសុទ្ធជាច្រើនបានរស់ឡើងវិញនិងនាំគ្នាចេញពីផ្នូរ។ ព្រឹត្តិការណ៍នេះ ណែនាំឲ្យទាហានពោលថា៖ «លោកនេះ ពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន!»។

នៅពេលយើងស្តាប់អត្ថបទថ្ងៃនេះ មានសំណួរខ្លះៗដែលចូលនៅក្នុងបរិយាកាសនិងស្ថានភាពនៃពិភពលោករបស់យើងសព្វថ្ងៃ។ សព្វថ្ងៃ យើងមិនវាយព្រះយេស៊ូ យើងមិនមើលងាយឬស្អប់ព្រះយេស៊ូ ប៉ុន្តែយើងមើលពិភពលោករបស់យើង មើលសង្គមរបស់យើង មើលរបៀបដែលយើងរស់នៅ មើលសង្គ្រាមដែលមាននៅប៉ុន្មានប្រទេស។ មើលការស្អប់គ្នា មើលមនុស្សដែលគ្មានម្ហូបអាហារ មើលមានប៉ុន្មានប្រទេសដែលចេះតែប្រកួតគ្នាដើម្បីមានលុយយ៉ាងច្រើន មើលពិភពលោករបស់យើងដែលបានបំផ្លាញទ្រព្យសម្បត្តិធម្មជាតិនៃផែនដី។ មើលមានប៉ុន្មានកន្លែងដែលកំពុងជិះជាន់អ្នកតូចតាច មើលមានប៉ុន្មាននាក់ដែលម្តាយបានយកកូនចេញពីផ្ទៃពោះ មើលមានប៉ុន្មានគ្រួសារដែលប្រើអំពើហិង្សាបណ្តាលឲ្យបាក់បែកគ្នា មើលមានមិត្តភាពប៉ុន្មានដែលបាត់បង់ដោយការក្បត់គ្នា។ មើលមានកូនក្មេងប៉ុន្មាននាក់ដែលធ្វើការមិនទាន់គ្រប់

អាយុ មើលមានប៉ុន្មានកន្លែងដែលពិភពលោករីកចម្រើនយ៉ាងលឿន ប៉ុន្តែអ្នកតូចតាចមិនអាចចូលរួមនៅក្នុងការរីកចម្រើននេះបាន មើលមានអ្នកក្រីក្រប៉ុន្មាននាក់ដែលគ្មានដី គ្មានផ្ទះ គ្មានសមត្ថភាពឲ្យកូនរៀនឬទៅមន្ទីរពេទ្យ។ មើលពិភពលោករបស់យើងចែកជាពីរ មួយសង្គមដែលពោរពេញដោយលុយយ៉ាងច្រើន និងសង្គមមួយទៀតគ្មានអ្វីសោះ មើលមានប៉ុន្មានកន្លែងដែលបានយកលុយជំនួសព្រះជាម្ចាស់។ មើលមានប៉ុន្មាននាក់ដែលបានជំពាក់លុយគេនិងគ្មានសមត្ថភាពសង មើលការបំផ្លាញព្រៃឈើដើម្បីផលប្រយោជន៍មនុស្សមួយចំនួនតូច មានប្រជាជនមួយចំនួនបានគេចខ្លួនពីផ្ទះរបស់គេស្នាក់នៅក្នុងជំរំ មានមនុស្សជាច្រើនបានចេញពីប្រទេសផ្ទាល់ខ្លួនដោយសារសង្គ្រាម ដោយសារបញ្ហានយោបាយ។ មើលមានមនុស្សប៉ុន្មាននាក់ដែលនៅលើកប៉ាល់ក្នុងមហាសមុទ្រ ដែលគ្មានប្រទេសណាចង់ទទួលស្វាគមន៍ មើលមានប៉ុន្មានប្រទេសដែលបានសាងសង់អាវុធប្រល័យលោក។

នេះទាំងអស់ **តើមិនមែនជាការប្រមាថព្រះជាម្ចាស់ទេឬ? តើមិនមែនជារបៀបដែលណែនាំឲ្យព្រះយេស៊ូរងទុក្ខលំបាកទេឬ? តើមិនមែនជារបៀបដែលយើងបង្ហាញការស្អប់ចំពោះព្រះយេស៊ូទេឬ?** នៅក្នុងពិភពលោករបស់យើងមានភាពអយុត្តិធម៌យ៉ាងខ្លាំង មានការជិះជាន់សិទ្ធិមនុស្សយ៉ាងច្រើន ណែនាំឲ្យមនុស្សមួយចំនួនរីកចម្រើនយ៉ាងខ្លាំង មួយចំនួនគ្មានអ្វីសោះ។ ប៉ុន្តែ នៅក្នុងប្រទេសនីមួយៗយើងដឹងថាយើងមានបងប្អូនយើង ដូចលោកស៊ីម៉ូនដែលបានជួយលីឈើឆ្កាងព្រះយេស៊ូ យើងមានបងប្អូនដែលសុខចិត្តយកថ្នាំដើម្បីព្យាបាលរបួស ដែលសម្លឹងមើលព្រះយេស៊ូនៅក្នុងការអធិដ្ឋាន ដែលបម្រើអ្នកក្រីក្រនិងអ្នកជំងឺ ដែលយកចិត្តទុកដាក់ជាមួយមនុស្សដែលគ្មានទីពឹង។ នៅក្នុងខែមករា ឆ្នាំ២០២០ ពេលនោះវាំងននរហែកជាពីរ ផែនដីរញ្ជួយ ផ្ទាំងថ្មប្រេះជាចេញពីគ្នា យើងអាចនិយាយថា កូវីដ១៩ គឺបានធ្វើហ្នឹងនៅក្នុងពិភពលោក។ នៅពេលនោះ ពិភពលោករបស់យើងបានភ្ញាក់នៅក្នុងសុបិនអាក្រក់បំផុត ពីប្រទេសចិនដល់ទ្វីបអាស៊ីខាងជើង ពីទ្វីបអឺរ៉ុបដល់ទ្វីបអាមេរិក។ សព្វថ្ងៃ ពិភពលោកកំពុងបិទទ្វារ ពិភពលោកកំពុងភ័យខ្លាចនូវសេចក្តីស្លាប់ដែលដើរជុំវិញយើង ដូចយើងឃើញជាក់ស្តែងពីមួយថ្ងៃទៅមួយថ្ងៃមានប៉ុន្មាននាក់ដែលបានស្លាប់ដោយសារមេរោគក្លូរូណានេះ។

ពិភពលោករបស់យើងសព្វថ្ងៃដូចនៅសម័យដើម មានលោកស៊ីម៉ូនផង មានស្ត្រីៗផង មានលោកយ៉ូសែបផង គឺក្រុមគ្រូពេទ្យនិងក្រុមការងារនៅក្នុងមន្ទីរពេទ្យ មហាជនដែលបន្តធ្វើការបងប្អូនទាំងអស់ដែលបានណែនាំឲ្យអ្នកកំពុងរងទុក្ខលំបាក បានរកឃើញការលើកទឹកចិត្ត និងសេចក្តីសង្ឃឹមខ្លះៗ។ នៅប្រទេសកម្ពុជាយើងស្ថិតនៅក្នុងស្ថានភាពល្អម ប៉ុន្តែឲ្យយើងការពារគ្នាទៅវិញទៅមក តាមដានព័ត៌មានពីរដ្ឋាភិបាល។ ជាពិសេស ឲ្យយើងយកចិត្តទុកដាក់អធិដ្ឋាន

សម្លឹងមើលព្រះយេស៊ូ ដើម្បីស្រឡាញ់ ដើម្បីបម្រើបងប្អូនរបស់យើង បម្រើប្រទេសរបស់យើង បម្រើអ្នកតូចតាច ឲ្យយើងខិតខំរស់នៅក្នុងភាពយុត្តិធម៌ សេចក្ដីស្រឡាញ់ ការលើកលែងទោស និងសេចក្ដីពិត។ ពេលយើងរួមគ្នា យើងអាចនិយាយថា "**លោកនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន**" សូមព្រះបន្ទូលនេះទៅជាព្រះបន្ទូលសម្រាប់យើងនៅក្នុងពេលវេលានេះ។ ពេញមួយសប្ដាហ៍ខាងមុខនេះ យើងឥតមានឱកាសដើម្បីអធិដ្ឋានរួមគ្នា យើងចូលនៅក្នុងសប្ដាហ៍ពិសិដ្ឋ ព្រះយេស៊ូជប់លៀងចុងក្រោយ ព្រះយេស៊ូរងទុក្ខលំបាក ព្រះយេស៊ូសោយទិវង្គត ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ប៉ុន្តែ សូមយកពេលទូលអង្វរព្រះជាម្ចាស់សូមឲ្យព្រះអង្គជួយយើងកែប្រែចិត្តគំនិត សង្គ្រោះយើង និងណែនាំឲ្យយើងមានជំនឿរឹងមាំ ដើម្បីប្រកាសថា "**លោកនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន**"។ រួមគ្នា យើងចូលនៅក្នុងទុក្ខលំបាករបស់ព្រះយេស៊ូ យើងមានចិត្តគំនិតតែមួយជាមួយគ្នា រួមគ្នាយើងត្រៀមខ្លួនទុកជាមុនដើម្បីជួយគ្នានៅពេលកូវីដ១៩ចេញផុតហើយ ឲ្យយើងធ្វើជាសាក្សីនៃការកសាងសេចក្ដីសុខសាន្ត និងយុត្តិធម៌ ដើម្បីកសាងពិភពមួយដែលយកវត្តមានរបស់ព្រះជាម្ចាស់ជាអាទិភាព យកជីវិតរបស់មនុស្សទាំងអស់ជាអាទិភាព យកស្ថេរភាពនៃបរិស្ថាននិងធម្មជាតិជាអាទិភាព។ នេះជាពិភពលោកមួយ ដែលយើងអាចរស់នៅប្រកបដោយសុខដុមរមនា ដោយចេះស្រឡាញ់ ដោយចេះបម្រើ និងដោយចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ អាម៉ែន៕